February 13, 2019

# ភាគីពាក់ព័ន្ធជឿជាក់ថា EBAអាចសង្គ្រោះបានបើអ្នកនយោបាយមានឆន្ទៈក្នុងការដោះស្រាយ



*សហភាពអឺរ៉ុប @សហការី*

*ដោយ អេង គីមហុង*12/02/2019 rfi

*ក្រោយពីគណៈកម្មការអឺរ៉ុបសម្រេចចាប់ផ្ដើមដំណើរការនីតិវិធី ដែលអាចឈានទៅដល់ការដកការអនុគ្រោះពន្ធនាំទំនិញចូលសហភាពអឺរ៉ុប*(EBA) *រដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធនានា នៅក្នុងប្រទេសកម្ពុជា បានបង្ហាញការសោកស្ដាយផង ស្ដីបន្ទោសស្ថានការណ៍ផង និង ផ្ដល់អនុសាសន៍ផង។*

*ដោយជូនគ្នានឹងការសម្រេចរបស់គណៈកម្មការអឺរ៉ុបពីដំណើរការនីតិវិធីដក* EBA *ពីកម្ពុជានៅថ្ងៃទី១២ខែកុម្ភៈនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ចេញសារតាមទំព័រហ្វេសប៊ុកនៅព្រឹកថ្ងៃអង្គារនេះថា ស្ថានភាពនយោបាយ សង្គម និងសេដ្ឋកិច្ច របស់កម្ពុជាសព្វថ្ងៃ កំពុងឆ្ពោះទៅរកភាពកាន់តែល្អប្រសើរ។ ជាក់ស្ដែងចំណូលពន្ធបានកើនឡើងជាបន្តបន្ទាប់ បន្ទាប់ពីសេដ្ឋកិច្ចកម្ពុជាពីមុនហ៊ុំព័ទ្ធដោយទារុណកម្មនិងការកៀបសង្កត់។*

លោក ហ៊ុន សែន បន្តថា កម្ពុជាធ្លាប់ជាប្រទេសក្រីក្រ ប៉ុន្តែឥឡូវគឺបានងើបលេចធ្លោររួចផុតពីភាពក្រីក្រជាមួយនឹងកំណើនសេដ្ឋកិច្ចក្នុងរង្វង់៧ភាគរយ។ ដូច្នេះកម្ពុជាមិនអាចពឹងលើជំនួយបរទេសតែមួយមុខទេ ហើយកម្ពុជាក៏មិនត្រូវយកឯករាជ្យភាព និងអធិបតេយ្យភាពរបស់ខ្លួនទៅដោះដូរជាថ្នូរនឹងអ្វីមួយនោះដែរ។ ប៉ុន្តែកម្ពុជាចង់ធ្វើជាមិត្តល្អជាមួយបណ្ដាប្រទេសដៃគូដែលចង់ឃើញកម្ពុជាកាន់តែរីកចម្រើនទៅមុខពិតប្រាកដដោយគ្មានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង។

តែចំពោះលោក អេង ឆៃអ៊ាង អនុប្រធានអតីតគណបក្សសង្គ្រោះជាតិ ដែលកំពុងនិរទេសខ្លួននៅឯក្រៅប្រទេសមិនគិតដូច្នោះទេ។ លោក អេង ឆៃអ៊ាង បានបង្ហាញសារខ្លីមួយនៅលើហ្វេប៊ុករបស់លោកដែរថា«កូនសោរ EBA ស្ថិតនៅលើដៃ លោក ហ៊ុន សែន។ បាត់ឬនៅអាស្រ័យលើ លោក ហ៊ុន សែន»។
ទន្ទឹមនឹងនេះ សភាពាណិជ្ជកម្មអឺរ៉ុប EuroCham Cambodia ដែលតំណាងក្រុមហ៊ុនចំនួន ៣៥០លើកឡើងដែរថា ការផ្ដើមជាផ្លូវការនូវដំណើរការនីតិវិធី ដែលអាចព្យួរប្រព័ន្ធអនុគ្រោះពន្ធ EBA ពីកម្ពុជា ជាការធ្វើឲ្យខូចប្រយោជន៍នៃការវិវត្តន៍របស់សង្គមសេដ្ឋកិច្ចកម្ពុជា។ សភាពាណិជ្ជកម្មអឺរុប បានសោកស្ដាយចំពោះសេចក្ដីសម្រេចនេះ ប៉ុន្តែនៅតែប្ដេជ្ញាបន្តភាពជាដៃគូ និងទំនាក់ទំនងជាមួយរដ្ឋាភិបាលកម្ពុជា ក្នុងទិសដៅជំនួញ និងការអភិវឌ្ឍ។

ជាមួយគ្នានេះ ស្ថានទូតអាមេរិកប្រចាំកម្ពុជា មានកង្វល់ដូចគ្នានឹងសហភាពអឺរ៉ុបដែរ ទាក់ទងនឹងការរំលោភយ៉ាងធ្ងន់ធ្ងរ លើសេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិការងារដែលមានការទទួលស្គាល់ជាអន្តរជាតិ និងសេរីភាពទាក់ទងនឹងអង្គការសមាគម។ តាមរយៈសេចក្ដីថ្លែងការណ៍បន្ទាន់មួយនៅថ្ងៃអង្គារនេះស្ថានទូតអាមេរិកកត់សម្គាល់ថា ការសម្រេចចិត្តរបស់សហភាពអឺរ៉ុប ក្នុងការផ្ដើមដំណើរការនីតិវិធីផ្អាកការអនុគ្រោះពន្ធក្នុងផ្នែកពាណិជ្ជកម្មដល់ប្រទេសកម្ពុជាដោយសារការដើរថយក្រោយយ៉ាងធ្ងន់ធ្ងរ ក្នុងការការពារសិទ្ធិមនុស្ស និងសិទ្ធិការងារ នៅក្នុងរយៈពេល១៨ ខែកន្លងទៅនេះ។

អាមេរិកក៏បានអំពាវនាវផងដែរ អោយប្រទេសកម្ពុជាទម្លាក់ចោលនូវបទចោទប្រកាន់លើលោក កឹម សុខា និងការចោទប្រកាន់តាមទំនើងចិត្តទាំងអស់ ប្រឆាំងនឹងអ្នកទោសនយោបាយដទៃទៀត ហើយអនុញ្ញាតអោយសហជីព អង្គការសារព័ត៌មានឯករាជ្យ និងក្រុមដទៃទៀតនៃសង្គមស៊ីវិល ដំណើរការដោយគ្មានការរឹតត្បិតដែលមិនត្រឹមត្រូវ។

សហរដ្ឋអាមេរិក អំពាវនាវឲ្យកម្ពុជា ស្តារឡើងវិញនូវលទ្ធិប្រជាធិបតេយ្យ ពហុបក្សពិតប្រាកដ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ព្រោះថា ថ្នាក់ដឹកនាំកម្ពុជានៅមានឱកាសនៅឡើយ ជៀសផុតពីផលវិបាកអវិជ្ជមានផ្នែកសេដ្ឋកិច្ចនៃការដកការអនុគ្រោះពន្ធ EBA។

ដំណាលគ្នានេះ លោក ប៉ាវ ស៊ីណា ប្រធានសហភាពចលនាកម្មករកម្ពុជាមើលឃើញថា រដ្ឋាភិបាលនិងអ្នកនយោបាយពាក់ព័ន្ធនៅមានពេលជិត១ឆ្នាំទៀតធ្វើកិច្ចការរួមគ្នាដើម្បីឆ្លើយតបតម្រូវការសហភាពអឺរ៉ុប។ តម្រូវការរបស់អឺរ៉ុបដែល លោក ប៉ាវ ស៊ីណា សំដៅដល់គឺ សិទ្ធិមនុស្ស សិទ្ធិកម្មករ និងសិទ្ធិសហជីពជាដើម។

ផ្ទុយមកវិញ លោក កាំង ម៉ូនីកា អគ្គលេខាធិការរងនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) មិនសូវជាភ្ញាក់ផ្អើលប៉ុន្មានទេចំពោះការប្រកាសរបស់សហភាពអឺរ៉ុប ជុំវិញនីតិវិធីនៃដំណើការដកប្រពន្ធអនុគ្រោះពន្ធ។ មិនភ្ញាក់ផ្អើលព្រោះវិស័យឯកជន តួយ៉ាងសមាគមរោងចក្រ និងរដ្ឋាភិបាលបានត្រៀមទុកជាមុនរួចហើយ។ ការត្រៀមខ្លួនទុកជាមុននៅក្នុងការធ្វើកំណែទម្រង់កាត់បន្ថយថ្លៃដើមនៃការផលិតរបស់កម្ពុជាដើម្បីមានលទ្ធភាពប្រកួតប្រជែងជាមួយប្រទេសក្បែរខាងក្នុងការនាំចេញ ក្នុងករណីដែលកម្ពុជាត្រូវបានតម្រូវឲ្យបង់ពន្ធនោះ។ បន្ថែមលើនេះកម្មករកម្មការិនី ប្រឹងប្រែងផលិតភាពការងារតាមរយៈការបន្ថែមថ្លៃធ្វើការកាត់បន្ថយថ្លៃសំរាក។

លោក កាំង ម៉ូនីកា យល់ថា បើមួយផ្នែក អឺរ៉ុបទាញហេតុផលនៃសិទ្ធិកម្មករនិងសហជីពដើម្បីដកប្រពន្ធអនុគ្រោះពន្ធ ជាមូលហេតុមិនសមទំនងព្រោះថា កម្មករ និងសហជីពក្នុងវិស័យកាត់ដេរនៅកម្ពុជាមានសិទ្ធិសេរីភាពពេញលេញក្នុងការតវ៉ា៕